ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣៣៩៨

(35)

ក្រសួងសុខាភិបាល

លេខ: 004 ...

ភ្នំពេញ, ថ្ងៃទី ... ខែ ... ឆ្នាំ២០០៦

# សារាចរ

## នៃសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសុខាភិបាល

ជំរាបមក

- លោកនាយក មន្ទីរពេទ្យជាតិ-នាយកមជ្ឈមណ្ឌលក្រោមឱវាទ
- លោកនាយក មន្ទីរសុខាភិបាលខេត្ត-ក្រុង
- គ្រប់ម្ចាស់ សេវាគ្លីនិកឯកជនទាំងអស់

**កម្មវត្ថុ:** ស្តីពីការប្រើប្រាស់រថយន្តគិលានសង្គ្រោះ (Ambulance) ។

**យោង:** សេចក្តីណែនាំលេខ ០១២អបស/មព ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០០ ស្តីពីការប្រើប្រាស់រថយន្តគិលានសង្គ្រោះ ។

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជំរាបលោកថា កន្លងមកក្រសួងសុខាភិបាល សង្កេតឃើញរថយន្តគិលានសង្គ្រោះរបស់រដ្ឋមួយចំនួនតូច ព្រមទាំងរបស់គ្លីនិកឯកជនប្រើប្រាស់មិនបានសមស្រប និងគ្មានផ្លាកសញ្ញាត្រឹមត្រូវតាមគោលការណ៍ណែនាំរបស់ក្រសួង ។

អាស្រ័យហេតុនេះ សូមលោកនាយក និងម្ចាស់គ្លីនិកឯកជនទាំងអស់យកចិត្តទុកដាក់សារជាថ្មីអនុវត្តអោយបានត្រឹមត្រូវដូចតទៅ :

**១-ចំពោះរថយន្តគិលានសង្គ្រោះរបស់រដ្ឋ :**

-ត្រូវបំពាក់ផ្លាកលេខរាជការអោយបានត្រឹមត្រូវ ។

-ត្រូវសរសេរ អក្សរឈ្មោះរថយន្តគិលានសង្គ្រោះ (Ambulance) និងឈ្មោះមន្ទីរពេទ្យ ឬមជ្ឈមណ្ឌល ជាអក្សរពណ៌ក្រហម ជាភាសាខ្មែរ និងភាសាបារាំង ឬអង់គ្លេស ដោយទំហំអក្សរសរសេរអោយបានសមរម្យទៅនឹងជញ្ជាំងរថយន្ត និងបិទផ្លាកសញ្ញា logo សង្គ្រោះបន្ទាន់លើផ្ទៃនៃជញ្ជាំងរថយន្តទាំងសងខាង ។

-ហាមបើកភ្លើងសញ្ញា ឬ ស៊ីរ៉ែនដើម្បីធ្វើចរាចរតាមផ្លូវពេលគ្មានករណីសង្គ្រោះបន្ទាន់ ។

-ហាមយករថយន្តគិលានសង្គ្រោះទៅធ្វើដំណើរកំសាន្តជាលក្ខណៈគ្រួសារ និងដឹកសំភារៈផ្សេងៗ

ក្រៅពីដឹកអ្នកជំងឺ ។

២-<u>ចំពោះរថយន្តគិលានសង្គ្រោះរបស់គ្លីនិកឯកជន</u> :

-ត្រូវសរសេរអក្សររថយន្តគិលានសង្គ្រោះ (Ambulance) និងសរសេរឈ្មោះមន្ទីរពហុព្យាបាល ឬមន្ទីរសំរាកព្យាបាល ឬមន្ទីរសម្ភព ឬគ្លីនិក ជាអក្សរពណ៌ខៀវទឹកប៊ិច សរសេរជាភាសាខ្មែរ និងបារាំង ឬអង់គ្លេស ដោយទំហំអក្សរសរសេរអោយបានធំ សមរម្យទៅនឹងផ្ទៃជញ្ជាំងរថយន្ត ។

-ត្រូវបិទ LogoClinic របស់ក្រសួងសុខាភិបាល និង គូសសញ្ញាកាកបាទពណ៌ខៀវទឹកប៊ិចនៅលើជញ្ជាំងរថយន្តទាំងសងខាង ( ហាមប្រើពណ៌ក្រហម) ។

-គ្រប់ម្ចាស់សេវាឯកជនទាំងអស់ ត្រូវយករថយន្ត គិលានសង្គ្រោះរបស់ខ្លួនមកពិនិត្យនិងចុះបញ្ជីនៅក្រសួងសុខាភិបាលដើម្បីសុំផ្លាកសញ្ញា LogoClinic ។

-ត្រូវ មានប័ណ្ណសំគាល់ព្រមទាំងផ្លាកលេខយានយន្តត្រឹមត្រូវចេញដោយក្រសួងសាធារណៈការនិងដឹកជញ្ជូន ព្រមទាំងចុះបញ្ជីរនៅគុំរូតចរាចរខេត្ត ក្រុង ។

-ហាមប្រើប្រាស់រថយន្តគិលានសង្គ្រោះនេះដឹកគ្រួសារកំសាន្ត ឬប្រកបរបររកស៊ីដឹកសំភារៈផ្សេងៗក្រៅពីដឹកអ្នកជំងឺដែលត្រូវសង្គ្រោះ ។

ករណីម្ចាស់គ្លីនិកឯកជនណាដែលមិនគោរពតាមការណែនាំនេះ ក្រសួងសុខាភិបាលនិងមានវិធានការបង្ក្រាបតាមនិតិវិធីនៃច្បាប់ ។

សូមលោកនាយកនិងម្ចាស់គ្លីនិកឯកជនទាំងអស់ យកចិត្តទុកដាក់អនុវត្តអោយបានល្អតាមខ្លឹមសារណែនាំនៃសារាចរនេះអោយមានប្រសិទ្ធិភាព ។

សូមលោកនាយកទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

វេជ្ជ. ហុង - ស៊ុនហុត

<u>ចំម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-សាលាក្រុងភ្នំពេញ
-អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
-អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
-នាយកដ្ឋានមន្ទីរពេទ្យ
-មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌល
-មន្ទីរសុខាភិបាលខេត្ត ក្រុង
-គ្រប់គ្លីនិកឯកជន
-ឯកសារ កាលប្បវត្តិ